ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៨៩ រ៉ែ.ថប.ប្រក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងអាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៧.សរណន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ស្តីពីវិធានការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលាសិលា
- បានឃើញប្រកាសលេខ០២១៤ រថ.នក.ប្រក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការផ្ទេរប្រតិភូកម្មមុខងារ ក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងអាជ្ញាបណ្ណ ដល់បុគ្គលដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដែលត្រូវមានហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមានមធ្យោបាយដឹកជញ្ជូន ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលដែលមានបំណងស្នើសុំ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងអាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមដែលត្រូវមានហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមានមធ្យោបាយដឹកជញ្ជូន។

**ប្រការ៣ .-**

បច្ចេកសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចខាងក្រោម៖

បុគ្គល សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល។

**មូលដ្ឋានអាជីវកម្ម** សំដៅដល់ទីតាំងធ្វើសកម្មភាពផ្នែកដោនស្ទ្រីម ឬមណ្ឌលសំចតយានយន្តដឹកជញ្ជូន។

**លិខិតអនុញ្ញាត** សំដៅដល់ឯកសារផ្លូវការចេញដោយរដ្ឋបាលរាជធានី ខេត្ត ក្នុងការអនុញ្ញាតឱ្យបុគ្គលណាមួយធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដូចមានចែងក្នុងប្រការ១៤នៃប្រកាសនេះ នៅក្នុងមូលដ្ឋានរបស់ខ្លួន។

**វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព** សំដៅដល់ឯកសារផ្លូវការចេញដោយក្រសួងរ៉ែនិងថាមពលក្នុងការបញ្ជាក់អំពីភាពអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ដោយបុគ្គលដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ។

**ស្ថានីយប្រេងឥន្ធនៈ** សំដៅដល់ស្ថានីយប្រេងឥន្ធនៈលើដី និងស្ថានីយប្រេងឥន្ធនៈលើទឹក។

**ស្ថានីយប្រេងឥន្ធនៈលើដី** សំដៅដល់ទីតាំងអាជីវកម្មប្រេងឥន្ធនៈលើដីដែលមានលទ្ធភាពផ្ទុកប្រេងឥន្ធនៈចាប់ពី ២០១ លីត្រ ដល់ ១៥០ ០០០ លីត្រ សម្រាប់ចាក់បញ្ចូលយានយន្តដល់សាធារណជន។

**ស្ថានីយប្រេងឥន្ធនៈលើទឹក** សំដៅដល់ទីតាំងអាជីវកម្មប្រេងឥន្ធនៈស្ថិតនៅលើទឹក អណ្តែតទឹក ឬបណ្តែតទឹក ដែលមានលទ្ធភាពផ្ទុកប្រេងឥន្ធនៈចាប់ពី ២០១ លីត្រ ដល់ ១៥០ ០០០ លីត្រ សម្រាប់ចាក់បញ្ចូលយានយន្តដល់សាធារណជន។

**ស្ថានីយឧស្ម័នឥន្ធនៈ** សំដៅដល់ទីតាំងអាជីវកម្មឧស្ម័នឥន្ធនៈលើដីដែលមានលទ្ធភាពផ្ទុកឧស្ម័នឥន្ធនៈចាប់ពី ១០១ គីឡូក្រាម ដល់ ៥០ ០០០ គីឡូក្រាម សម្រាប់ចាក់បញ្ចូលយានយន្តដល់សាធារណជន។

**ស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ** សំដៅដល់ទីតាំងអាជីវកម្មប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈលើដីដែលមានលទ្ធភាពផ្ទុកប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈចាប់ពី ២០១ លីត្រ ដល់ ១៥០ ០០០ លីត្រ (សមមូលប្រេងឥន្ធនៈ) សម្រាប់ចាក់បញ្ចូលយានយន្តដល់សាធារណជន។

សកម្មភាពវេចខ្ចប់ សំដៅដល់សកម្មភាពបញ្ចូល ឬច្រកនូវផលិតផលប្រេងកាតក្នុងកំប៉ុង ឬ ធុង។

អាជ្ញាបណ្ណ សំដៅដល់ឯកសារផ្លូវការចេញដោយក្រសួងរ៉ែនិងថាមពល ក្នុងការអនុញ្ញាតឱ្យនីតិបុគ្គលណាមួយធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដូចមានចែងក្នុងប្រការ១៤ នៃប្រកាសនេះ។

## ជំពូកទី ២

## នីតិវិធីនៃការដាក់ពាក្យស្នើសុំ និងការពិនិត្យផ្តល់យោបល់លើពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម

**ប្រការ៤ .-**

បុគ្គលដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមរួមមាន ការធ្វើប្រព្រឹត្តិកម្ម ការដឹកជញ្ជូន សន្និធិ និងពាណិជ្ជកម្មប្រេងកាតនិងផលិតផលប្រេងកាត ដែលត្រូវមានហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមានមធ្យោបាយដឹកជញ្ជូនដើម្បីបម្រើឱ្យសកម្មភាពទាំងនេះ ត្រូវសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព។

រាល់ការកែប្រែ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមធ្យោបាយដឹកជញ្ជូនដែលមានស្រាប់ ដែលមិនមែនជាការកំណត់លក្ខខណ្ឌឱ្យកែសម្រួលរបស់ក្រសួងរ៉ែនិងថាមពល រួមមាន ការកែប្រែទ្រង់ទ្រាយមុខងារប្រើប្រាស់ ឬផ្នែកណាមួយនៃហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬបន្ថែមមធ្យោបាយដឹកជញ្ជូន ដែលទាំងនេះអាចនឹងបណ្តាលឱ្យប៉ះពាល់ដល់សុវត្ថិភាព ត្រូវសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពថ្មីចេញដោយក្រសួងរ៉ែនិងថាមពល មុននឹងចាប់ផ្តើមធ្វើការកែប្រែ ការពង្រីក ឬការបន្ថែមនោះ។

### ផ្នែកទី១

### វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ

**ប្រការ៥ .-**

បុគ្គលដែលមានបំណងស្នើសុំ ឬបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ ឬស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការកែប្រែ ឬការពង្រីកហេដ្ឋារចនាសម្ព័ន្ធស្ថានីយ ឬស្នើសុំផ្ទេរសិទ្ធិពាក់ព័ន្ធស្ថានីយ អាចទទួលពាក្យស្នើសុំនៅមន្ទីររ៉ែនិងថាមពល ដែលស្ថានីយនោះស្ថិតនៅ ឬគេហទំព័រក្រសួងរ៉ែនិងថាមពលដែលមានអាសយដ្ឋាន www.mme.gov.kh។

**ប្រការ៦ .-**

បុគ្គលដែលមានបំណងស្នើសុំឬបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

បុគ្គលដែលមានបំណងស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ការកែប្រែ ឬការពង្រីកហេដ្ឋារចនាសម្ព័ន្ធស្ថានីយដូចមានចែងក្នុងប្រការ៥នៃប្រកាសនេះ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

បុគ្គលដែលមានបំណងស្នើសុំផ្ទេរសិទ្ធិពាក់ព័ន្ធស្ថានីយដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ៧ ._**

បុគ្គលដែលមានបំណងស្នើសុំស្របតាមប្រការ៥ នៃប្រកាសនេះ ត្រូវដាក់ពាក្យស្នើសុំនៅមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ដែលស្ថានីយនោះស្ថិតនៅ រៀងរាល់ថ្ងៃធ្វើការនិងម៉ោងធ្វើការ។ មន្ត្រីនៃមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ភាពពេញលេញនៃពាក្យស្នើសុំ និងឯកសារពាក់ព័ន្ធដែលភ្ជាប់មកជាមួយ។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមានភាពពេញលេញ មន្ត្រីនៃមន្ទីររ៉ែនិងថាមពលត្រូវចេញបង្កាន់ដៃទទួលពាក្យស្នើសុំជូនបុគ្គលស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី៥នៃប្រកាសនេះ បន្ទាប់ពីទទួលបានឯកសារភស្តុតាងនៃការបង់ប្រាក់។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមិនទាន់ពេញលេញ មន្ត្រីទទួលពាក្យត្រូវបដិសេធពាក្យស្នើសុំ ហើយណែនាំឱ្យបុគ្គលស្នើសុំទៅបំពេញបន្ថែមនិងដាក់ពាក្យជាថ្មី ។

**ប្រការ៨ ._**

ពាក្យស្នើសុំពាក់ព័ន្ធនឹងស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ ត្រូវពិនិត្យនិងផ្តល់យោបល់តាមនីតិវិធីដូចខាងក្រោម៖

ក- មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត៖

- ត្រូវថតចម្លងជាឯកសារទន់ រួចផ្ញើចូលក្រុមប្រព័ន្ធដែលមានសមាសភាព មន្ទីររ៉ែនិងថាមពល ច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល នាយកដ្ឋានទទួលបន្ទុក ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត និងថ្នាក់ដឹកនាំទទួលបន្ទុក ក្នុងរយៈពេល ១(មួយ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំនោះ និង
- ត្រូវចុះពិនិត្យទីតាំងជាក់ស្តែង ថតរូប និងរៀបចំកំណត់ហេតុ រួចថតចម្លងជាឯកសារទន់ផ្ញើចូលក្រុមប្រព័ន្ធក្នុងរយៈពេល៦(ប្រាំមួយ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានផ្ញើឯកសារទន់ចូលក្នុងក្រុមប្រព័ន្ធ រួច លើកលែងការស្នើសុំផ្ទេរសិទ្ធិដែលពុំចាំបាច់ចុះពិនិត្យទីតាំង។

ខ- ច្រកចេញ-ចូលតែមួយ និងនាយកដ្ឋានទទួលបន្ទុក៖

- មន្ត្រីច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ត្រូវបោះពុម្ពទំព័រទី១នៃពាក្យស្នើសុំដើម្បីបោះត្រានិងចុះលេខចូល និងចេញវិក្កយបត្របង់ចំណូលកម្រៃសេវាសាធារណៈ រួចផ្ញើចូលក្រុមប្រព័ន្ធក្នុងរយៈពេល ១(មួយ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណុំពាក្យស្នើសុំពេញលេញពីមន្ទីររ៉ែនិងថាមពលតាមរយៈក្រុមប្រព័ន្ធ
- នាយកដ្ឋានទទួលបន្ទុកត្រូវកត់ត្រាបញ្ចូលក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងស្ថានីយ និងពិនិត្យនិងធ្វើរបាយការណ៍វាយតម្លៃលើរូបភាពនិងកំណត់ហេតុចុះពិនិត្យទីតាំងរបស់មន្ទីររ៉ែនិងថាមពល រួចរៀបចំឯកសារជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេចក្នុងរយៈពេល១៣(ដប់បី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីនាយកដ្ឋានទទួលបានរូបភាព និងកំណត់ហេតុពីមន្ទីររ៉ែនិងថាមពល តាមរយៈក្រុមប្រព័ន្ធ។ ក្នុងករណីចាំបាច់ នាយកដ្ឋានអាចចុះបេសកកម្មពិនិត្យបន្ថែម។

គ- ថ្នាក់ដឹកនាំទទួលបន្ទុកនិងខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី៖

- ថ្នាក់ដឹកនាំទទួលបន្ទុកត្រូវពិនិត្យនិងសម្រេចលើសំណើក្នុងរយៈពេល ២(ពីរ) ថ្ងៃនៃថ្ងៃធ្វើការ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីត្រូវបោះត្រានិងចុះលេខលើឯកសារក្នុងរយៈពេល ១(មួយ)ថ្ងៃ នៃថ្ងៃធ្វើការ។

# ផ្នែកទី២
# វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ក្រៅពីស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ

**ប្រការ៩ .-**

បុគ្គលដែលមានបំណង ស្នើសុំ ឬបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមដែលត្រូវមានហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមធ្យោបាយដឹកជញ្ជូន ឬស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការកែប្រែ ឬការពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមធ្យោបាយដឹកជញ្ជូន ក្រៅពីស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ ឬស្នើសុំផ្ទេរសិទ្ធិ អាចទទួលពាក្យស្នើសុំនៅច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ឬគេហទំព័រក្រសួងរ៉ែនិងថាមពលដែលមានអាសយដ្ឋាន www.mme.gov.kh។

**ប្រការ១០ .-**

បុគ្គលដែលមានបំណង ស្នើសុំ ឬបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

បុគ្គលដែលមានបំណងស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការកែប្រែ ឬការពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីមឬមធ្យោបាយដឹកជញ្ជូនដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

បុគ្គលដែលមានបំណង ស្នើសុំផ្ទេរសិទ្ធិ ដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ១១ .-**

បុគ្គលដែលមានបំណងស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្របតាមប្រការ៩ នៃប្រកាសនេះ ត្រូវយកពាក្យស្នើសុំនោះទៅដាក់នៅច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល នៅរៀងរាល់ថ្ងៃធ្វើការនិងម៉ោងធ្វើការ។

មន្ត្រីដែលទទួលពាក្យស្នើសុំនៅច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ភាពពេញលេញនៃពាក្យស្នើសុំនីមួយៗ រួមទាំងសំណុំឯកសារពាក់ព័ន្ធដែលភ្ជាប់មកជាមួយ។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមានភាពពេញលេញ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យស្នើសុំជូនអ្នកដាក់ពាក្យស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមិនទាន់ពេញលេញ មន្ត្រីទទួលពាក្យត្រូវបដិសេធពាក្យស្នើសុំហើយណែនាំឱ្យបុគ្គលស្នើសុំទៅបំពេញបន្ថែមនិងដាក់ពាក្យជាថ្មី។

**ប្រការ១២ .-**

អគ្គនាយកដ្ឋានប្រេងកាតត្រូវពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសារស្នើសុំ ឬបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព ឬការកែប្រែ ឬការពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមធ្យោបាយដឹកជញ្ជូន ឬការផ្ទេរសិទ្ធិ តាមនីតិវិធីដូចខាងក្រោម៖

ក- ពិនិត្យឯកសារតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិបច្ចេកទេសដែលចេញ ឬទទួលស្គាល់ដោយក្រសួងរ៉ែនិងថាមពល។

ខ- មន្ត្រីជំនាញត្រូវចុះពិនិត្យទីតាំងស្នើសុំជាក់ស្តែង ដើម្បីធ្វើកំណត់ហេតុ លើកលែងការស្នើសុំផ្ទេរសិទ្ធិដែលពុំចាំបាច់ចុះពិនិត្យទីតាំង

គ- រៀបចំរបាយការណ៍និងកំណត់បង្ហាញរឿងជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលពិនិត្យនិងសម្រេច។

## ផ្នែកទី ៣
## សុពលភាពនៃវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព

### ប្រការ១៣ .-

វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ស្របតាមប្រការ៤នៃប្រកាសនេះ មានរយៈពេលសុពលភាពដូចខាងក្រោម៖

| ល.រ | សកម្មភាពដែលត្រូវមានហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬ មានមធ្យោបាយដឹកជញ្ជូន | រយៈពេល សុពលភាពដំបូង | រយៈពេលបន្ត សុពលភាព |
|---|---|---|---|
| ១ | ប្រព្រឹត្តិកម្ម | | |
| ១.១ | សមត្ថភាពផលិតសរុបចាប់ពី៥ ០០០ ០០០ (ប្រាំលាន)លីត្រឡើងទៅក្នុងមួយឆ្នាំ | ៥ ឆ្នាំ | មិនលើស ៤ ឆ្នាំ/ម្តង |
| ១.២ | សមត្ថភាពផលិតសរុបតិចជាង ៥ ០០០ ០០០ (ប្រាំលាន)លីត្រក្នុងមួយឆ្នាំ | ៥ ឆ្នាំ | មិនលើស ៣ ឆ្នាំ/ម្តង |
| ២ | សន្និធិ | | |
| ២.១ | ការស្តុកទុកប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាតដែលមានបរិមាណស្តុកសរុបលើសពី ១០ ០០០ ០០០(ដប់លាន)លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ ដែលមានបរិមាណស្តុកសរុបលើសពី ៥ ០០០ ០០០(ប្រាំលាន)គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួមដែលមានបរិមាណស្តុកសមមូលលើសពី ១០ ០០០ ០០០(ដប់លាន)លីត្រ | ៥ ឆ្នាំ | មិនលើស ៤ ឆ្នាំ/ម្តង |
| ២.២ | ការស្តុកទុកប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាតដែលមានបរិមាណស្តុកលើសពី ១ ០០០ ០០០(មួយលាន)លីត្រ ដល់១០ ០០០ ០០០(ដប់លាន)លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ ដែលមានបរិមាណស្តុកលើសពី ៥០០ ០០០(ប្រាំរយពាន់)គីឡូក្រាម ដល់ ៥ ០០០ ០០០(ប្រាំលាន)គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួមដែលមានបរិមាណស្តុកសមមូលលើសពី ១ ០០០ ០០០(មួយលាន)លីត្រ ដល់ ១០ ០០០ ០០០(ដប់លាន)លីត្រ | ៥ ឆ្នាំ | មិនលើស ៣ ឆ្នាំ/ម្តង |
| ២.៣ | ការស្តុកទុកប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាតដែលមានបរិមាណស្តុកលើសពី១៥០ ០០០ (មួយរយហាសិបពាន់)លីត្រ ដល់១ ០០០ ០០០(មួយលាន)លីត្រ | ៣ ឆ្នាំ | ៣ ឆ្នាំ/ម្តង |

| | | | |
|---|---|---|---|
| | ឬចំពោះឧស្ម័នឥន្ធនៈដែលមានបរិមាណស្តុកលើសពី ៥០ ០០០(ហាសិបពាន់)គីឡូក្រាម ដល់ ៥០០ ០០០ (ប្រាំរយពាន់)គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម ដែលមានបរិមាណស្តុកសមមូលលើសពី ១៥០ ០០០ (មួយរយហាសិបពាន់)លីត្រ ដល់ ១ ០០០ ០០០ (មួយលាន)លីត្រ | | |
| ២.៤ | ការស្តុកទុកប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត (ក្រៅពីប្រេងរំអិលក្នុងកំប៉ុងឬធុង) ដែលមានបរិមាណស្តុកចាប់ពី ២០១ (ពីររយមួយ)លីត្រ ដល់ ១៥០ ០០០ (មួយរយហាសិបពាន់)លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ (ក្រៅពីឧស្ម័នឥន្ធនៈក្នុងកំប៉ុងឬធុង) ដែលមានបរិមាណស្តុកចាប់ពី១០១ (មួយរយមួយ)គីឡូក្រាម ដល់ ៥០ ០០០ (ហាសិបពាន់)គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម ដែលមានបរិមាណស្តុកសមមូលចាប់ពី ២០១ (ពីររយមួយ)លីត្រ ដល់១៥០ ០០០(មួយរយហាសិបពាន់)លីត្រ | ២ ឆ្នាំ | ២ ឆ្នាំ/ម្តង |
| ៣ | **ដឹកជញ្ជូនតាមបំពង់បង្ហូរ** | ៥ ឆ្នាំ | មិនលើស ៤ ឆ្នាំ/ម្តង |
| ៤ | **ដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ** | | |
| ៤.១ | មធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុកលើសពី ៣ ០០០ (បីពាន់)លីត្រក្នុងមួយលើក ចំពោះប្រេងឥន្ធនៈ ឬលើសពី ១ ៥០០ (មួយពាន់ប្រាំរយ)គីឡូក្រាមក្នុងមួយលើក ចំពោះឧស្ម័នឥន្ធនៈ | ៣ ឆ្នាំ | ៣ ឆ្នាំ/ម្តង |
| ៤.២ | មធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុកចាប់ពី ២០១ (ពីររយមួយ)លីត្រ ដល់ ៣ ០០០ (បីពាន់)លីត្រក្នុងមួយលើក ចំពោះប្រេងឥន្ធនៈ ឬចាប់ពី ១០១ (មួយរយមួយ) គីឡូក្រាម ដល់ ១ ៥០០ (មួយពាន់ប្រាំរយ) គីឡូក្រាមក្នុងមួយលើក ចំពោះឧស្ម័នឥន្ធនៈ | ២ ឆ្នាំ | ២ ឆ្នាំ/ម្តង |
| ៥ | **វេចខ្ចប់** | | |
| ៥.១ | សមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំចាប់ពី ១៥០ ០០០ (មួយរយហាសិបពាន់)លីត្រឡើងទៅ ចំពោះផលិតផលប្រេងកាត ឬចាប់ពី ៥០ ០០០ (ហាសិបពាន់)គីឡូក្រាមឡើងទៅ ចំពោះឧស្ម័នឥន្ធនៈ | ៤ ឆ្នាំ | មិនលើស ៣ ឆ្នាំ/ម្តង |
| ៥.២ | សមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ តិចជាង ១៥០ ០០០ (មួយរយហាសិបពាន់)លីត្រ ចំពោះផលិតផលប្រេងកាត ឬតិចជាង ៥០ ០០០ (ហាសិបពាន់)គីឡូក្រាម ចំពោះឧស្ម័នឥន្ធនៈ | ៣ ឆ្នាំ | ២ ឆ្នាំ/ម្តង |
| ៦ | **ផ្គត់ផ្គង់និងចែកចាយ** | | |

| | | | |
|---|---|---|---|
| ៦.១ | សមត្ថភាពផ្គត់ផ្គង់និងចែកចាយតាមបណ្តាញបំពង់បង្ហូរសរុបក្នុងមួយឆ្នាំចាប់ពី ១៥០ ០០០ (មួយរយហាសិបពាន់) លីត្រឡើងទៅ ចំពោះប្រេងឥន្ធនៈ ឬចាប់ពី ៥០ ០០០ (ហាសិបពាន់)គីឡូក្រាមឡើងទៅ ចំពោះឧស្ម័នឥន្ធនៈ | ៤ ឆ្នាំ | មិនលើស ៣ ឆ្នាំ/ម្តង |
| ៦.២ | សមត្ថភាពផ្គត់ផ្គង់និងចែកចាយឧស្ម័នឥន្ធនៈតាមបណ្តាញបំពង់បង្ហូរសរុបក្នុងមួយឆ្នាំ តិចជាង ១៥០ ០០០ (មួយរយហាសិបពាន់)លីត្រ ចំពោះប្រេងឥន្ធនៈ ឬតិចជាង ៥០ ០០០ (ហាសិបពាន់)គីឡូក្រាម | ៣ ឆ្នាំ | ២ ឆ្នាំ/ម្តង |
| ៧ | ពាណិជ្ជកម្ម | | |
| | ការបង្កើតនិងដំណើរការស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ | ២ ឆ្នាំ | ២ ឆ្នាំ/ម្តង |

បុគ្គលទទួលបានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព ត្រូវមកដាក់ពាក្យស្នើសុំបន្តសុពលភាពនៃវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពខាងលើ ក្នុងរយៈពេលយ៉ាងតិច ៦០ (ហុកសិប)ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាពនៃវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព។

## ជំពូកទី ៣
## នីតិវិធីនៃការដាក់ពាក្យស្នើសុំ និងការពិនិត្យផ្តល់យោបល់លើពាក្យស្នើសុំលិខិតអនុញ្ញាត និងអាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម

**ប្រការ១៤ .-**

បន្ទាប់ពីទទួលបានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពពីក្រសួងរ៉ែនិងថាមពល និងបានរៀបចំនិងដំឡើងហេដ្ឋារចនាសម្ព័ន្ធឬមធ្យោបាយដឹកជញ្ជូនរួច បុគ្គលដែលធ្វើសកម្មភាពក្នុងផ្នែកដោនស្ទ្រីម ត្រូវស្នើសុំលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ខេត្ត ដែលមូលដ្ឋានអាជីវកម្មនោះស្ថិតនៅ ឬអាជ្ញាបណ្ណពីក្រសួងរ៉ែនិងថាមពល តាមការកំណត់ដូចខាងក្រោម៖

| ល.រ | សកម្មភាពដែលត្រូវមានហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមានមធ្យោបាយដឹកជញ្ជូន | ត្រូវសុំលិខិតអនុញ្ញាត | ត្រូវសុំអាជ្ញាបណ្ណ |
|---|---|---|---|
| ១ | ប្រព្រឹត្តិកម្ម ដែលមានសមត្ថភាពផលិតសរុបក្នុងមួយឆ្នាំ | ក្រោម ៥ ០០០ ០០០ (ប្រាំលាន)លីត្រ | ចាប់ពី ៥ ០០០ ០០០ (ប្រាំលាន) លីត្រឡើង |
| ២ | សន្និធិ ដែលមានបរិមាណស្តុកសរុប | -ចាប់ពី ២០១(ពីររយមួយ) លីត្រ ដល់ ១៥០ ០០០(មួយរយហាសិបពាន់) លីត្រ ចំពោះប្រេងឥន្ធនៈ និង | - លើសពី ១៥០ ០០០ (មួយរយហាសិបពាន់) លីត្រ ចំពោះប្រេងឥន្ធនៈ និង<br>- លើសពី ៥០ ០០០ |

| | | | |
|---|---|---|---|
| | | - ចាប់ពី ១០១ (មួយរយមួយ) គីឡូក្រាមដល់ ៥០ ០០០ (ហាសិបពាន់) គីឡូក្រាមចំពោះឧស្ម័នឥន្ធនៈ | (ហាសិបពាន់)គីឡូក្រាម ចំពោះឧស្ម័នឥន្ធនៈ |
| ៣ | ការដឹកជញ្ជូនតាមបំពង់បង្ហូរ | | ការដឹកជញ្ជូនប្រេងកាតនិងផលិតផលប្រេងកាតតាមបំពង់បង្ហូរ រួមបញ្ចូលបំពង់បង្ហូរមេនិងប្រព័ន្ធបំពង់បង្ហូររង |
| ៤ | ការដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ | ការដឹកជញ្ជូនផលិតផលប្រេងកាតតាមយានយន្តផ្លូវគោក ដែលមធ្យោបាយដឹកជញ្ជូននោះមានសមត្ថភាពផ្ទុកចាប់ពី ២០១ (ពីររយមួយ)លីត្រឡើងក្នុងមួយលើកចំពោះប្រេងឥន្ធនៈ ឬ ចាប់ពី ១០១ (មួយរយមួយ) គីឡូក្រាមឡើងក្នុងមួយលើកចំពោះឧស្ម័នឥន្ធនៈ | ការដឹកជញ្ជូនប្រេងកាត និងផលិតផលប្រេងកាតតាមមធ្យោបាយដឹកជញ្ជូនផ្លូវគោក ផ្លូវដែក និងផ្លូវទឹក (**លើកលែងការដឹកជញ្ជូនផលិតផលប្រេងកាតតាមយានយន្តផ្លូវគោក**) ដែលមធ្យោបាយដឹកជញ្ជូននោះមានសមត្ថភាពផ្ទុកចាប់ពី ២០១ (ពីររយមួយ)លីត្រ ឡើងក្នុងមួយលើកចំពោះប្រេងឥន្ធនៈ ឬ ចាប់ពី ១០១ (មួយរយមួយ) គីឡូក្រាមឡើង ក្នុងមួយលើកចំពោះឧស្ម័នឥន្ធនៈ |
| ៥ | ពាណិជ្ជកម្មសម្រាប់ | ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ | - ការវេចខ្ចប់ផលិតផលប្រេងកាត និង/ឬឧស្ម័នឥន្ធនៈ<br>- ការផ្គត់ផ្គង់និងចែកចាយ តាមបណ្តាញបំពង់បង្ហូរនូវផលិតផលប្រេងកាត និង/ឬឧស្ម័នឥន្ធនៈ |

## ផ្នែកទី១
## លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម

**ប្រការ១៥ .-**

បុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាតស្របតាមប្រការ១៤នៃប្រកាសនេះ អាចទទួលបានពាក្យស្នើសុំនៅអង្គភាពច្រកចេញ-ចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលមូលដ្ឋានអាជីវកម្មនោះស្ថិតនៅ និងអនុវត្តតាមប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារ ក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។

## ផ្នែកទី២
## អាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម

### ប្រការ១៦ .-

បុគ្គលដែលមានបំណង ស្នើសុំ ឬការបន្តសុពលភាព ឬការផ្ទេរសិទ្ធិអាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមដែលត្រូវមានហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមធ្យោបាយដឹកជញ្ជូន អាចទទួលបានពាក្យស្នើសុំនៅច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ឬគេហទំព័រក្រសួងរ៉ែនិងថាមពលដែលមានអាសយដ្ឋាន www.mme.gov.kh។

### ប្រការ១៧ .-

បុគ្គលដែលមានបំណងស្នើសុំ ឬ បន្តសុពលភាពអាជ្ញាបណ្ណដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

បុគ្គលដែលមានបំណងស្នើសុំផ្ទេរសិទ្ធិដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

### ប្រការ១៨ .-

បុគ្គលដែលមានបំណងស្នើសុំស្របតាមប្រការ១៦នៃប្រកាសនេះ ត្រូវយកពាក្យស្នើសុំនោះទៅដាក់នៅច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល នៅរៀងរាល់ថ្ងៃធ្វើការនិងម៉ោងធ្វើការ។

មន្ត្រីដែលទទួលពាក្យស្នើសុំនៅច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ភាពពេញលេញនៃពាក្យស្នើសុំនីមួយៗ រួមទាំងសំណុំឯកសារពាក់ព័ន្ធដែលភ្ជាប់មកជាមួយ។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមានភាពពេញលេញ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យស្នើសុំជូនអ្នកដាក់ពាក្យស្នើសុំតាមទម្រង់ដូចមាននៅក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមិនទាន់ពេញលេញ មន្ត្រីទទួលពាក្យត្រូវបដិសេធពាក្យស្នើសុំ ហើយណែនាំឱ្យបុគ្គលស្នើសុំទៅបំពេញបន្ថែមនិងដាក់ពាក្យជាថ្មី។

### ប្រការ១៩ .-

អគ្គនាយកដ្ឋានប្រេងកាតត្រូវពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារ ស្នើសុំ ឬការបន្តសុពលភាព ឬការផ្ទេរសិទ្ធិអាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមដែលត្រូវមានហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមធ្យោបាយដឹកជញ្ជូន តាមនីតិវិធីដូចខាងក្រោម៖

ក- ពិនិត្យឯកសារតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិបច្ចេកទេសដែលចេញ ឬទទួលស្គាល់ដោយក្រសួងរ៉ែនិងថាមពល។

ខ- មន្ត្រីជំនាញត្រូវចុះពិនិត្យទីតាំងស្នើសុំជាក់ស្តែង ដើម្បីធ្វើកំណត់ហេតុ លើកលែងការស្នើសុំផ្ទេរសិទ្ធិដែលពុំចាំបាច់ចុះពិនិត្យទីតាំង

គ- រៀបចំរបាយការណ៍និងកំណត់បង្ហាញរឿងជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលពិនិត្យនិងសម្រេច។

## ផ្នែកទី ៣
## សុពលភាពនៃអាជ្ញាបណ្ណ

**ប្រការ២០ .-**

អាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមស្របតាមប្រការ១៤ នៃប្រកាសនេះ មានរយៈពេលសុពលភាព ១០(ដប់)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការផ្តល់អាជ្ញាបណ្ណ។ បុគ្គលទទួលបានអាជ្ញាបណ្ណត្រូវមកដាក់ពាក្យស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណខាងលើ ក្នុងរយៈពេលយ៉ាងតិច ៦០(ហុកសិប)ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាពនៃអាជ្ញាបណ្ណ។

## ជំពូកទី ៤
## ការពិនិត្យ និងសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងអាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម

**ប្រការ២១ .-**

រយៈពេលនៃការពិនិត្យ និងសម្រេចលើពាក្យស្នើសុំដូចមានចែងក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរ៉ែនិងថាមពល។

**ប្រការ២២ .-**

ក្រសួងរ៉ែនិងថាមពល ត្រូវឆ្លើយតបលើពាក្យស្នើសុំទៅតាមលទ្ធផលនៃការពិនិត្យវាយតម្លៃលើសំណុំឯកសារនិងការពិនិត្យទីតាំងជាក់ស្តែង ដូចខាងក្រោម៖

- ឯកភាពតាមសំណើ
- ឯកភាពតាមសំណើដោយមានលក្ខខណ្ឌ
- ស្នើឱ្យបំភ្លឺបន្ថែម ឬ តម្រូវឱ្យបុគ្គលស្នើសុំធ្វើការកែសម្រួលបំពេញបន្ថែម ឬ
- ធ្វើការបដិសេធចំពោះពាក្យស្នើសុំដោយមានមូលហេតុនៃការសម្រេចជាលាយលក្ខណ៍អក្សរ។

## ជំពូកទី ៥
## ការបង់កម្រៃសេវាកម្ម

**ប្រការ២៣ .-**

បុគ្គលដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព អាជ្ញាបណ្ណ បន្តសុពលភាពនៃវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព បន្តសុពលភាពនៃអាជ្ញាបណ្ណ ឬការកែប្រែ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមធ្យោបាយដឹកជញ្ជូន ឬការផ្ទេរសិទ្ធិ ត្រូវបង់កម្រៃសេវាសាធារណៈស្របតាមប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**ប្រការ២៤ .-**

រាល់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ ដែលបានដាក់មកក្រសួងរ៉ែនិងថាមពលរួចហើយមុនប្រកាស

នេះចូលជាធរមាន  អគ្គនាយកដ្ឋានប្រេងកាតត្រូវបន្តចុះពិនិត្យទីតាំងនិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យនិងសម្រេចឱ្យចប់ក្នុងរយៈពេល ២ ខែ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ២៥ .-**

ប្រកាសលេខ០១១០ រថ.បវប.ប្រក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព លិខិតអនុញ្ញាត និងអាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៦ .-**

នាយកខុទ្ទកាល័យ  អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ៣ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**កែវ រតនៈ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ០១៨៩.២៤.ប/ឈុក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០២៤ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងអាជ្ញាបណ្ណ សម្រាប់សកម្មភាពផ្នែកជោនស្រ្តីម**

ទម្រង់ ១.១.១

# ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ស្ថានីយ
APPLICATION FORM FOR SAFETY TECHNICAL CERTIFICATE FOR FILLING STATION

រូបថតអ្នកស្នើសុំ
Photo of applicant
4 x 6

**១- ព័ត៌មានអំពីអ្នកស្នើសុំ (Applicant's Information)**

☐ រូបវន្តបុគ្គល (Natural Person) ☐ នីតិបុគ្គល (Legal Entity)

ឈ្មោះអ្នកស្នើសុំ៖ ______ សញ្ជាតិ៖ ______ ភេទ៖ ☐ ប្រុស ☐ ស្រី

Applicant's Name: ______ Nationality: ______ Sex: ☐ Male ☐ Female

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number): ______ ថ្ងៃខែឆ្នាំកំណើត (DoB): ______

អាសយដ្ឋានអ្នកស្នើសុំ (Address of Applicant): ______

______

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ______ អ៊ីម៉ែល (E-mail): ______

| |
|---|
| បំពេញព័ត៌មានខាងក្រោម ប្រសិនបើម្ចាស់អាជីវកម្មជានីតិបុគ្គល (Complete the Following If the Applicant is a Legal Entity)៖ |
| តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន ៖ ☐ ប្រធានក្រុមហ៊ុន (Chairperson/Managing Director) |
| Position of Applicant in Company/Firm : ☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (Duly Representative) |
| (សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង Please Attach Power of Attorney) |
| នាមករណ៍ក្រុមហ៊ុន ៖ ______ លេខចុះបញ្ជីពាណិជ្ជកម្ម : ______ |
| Firm/Company's Name : ______ (Business Registration No) |
| អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ (Office's Address) : ______ |
| លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ______ អ៊ីម៉ែល (E-mail) : ______ |

**២- ព័ត៌មានអំពីគម្រោងស្ថានីយ (Information on Filling Station Project)**

**២.១- ប្រភេទស្ថានីយ** (Type of Filling Station)

☐ ស្ថានីយប្រេងឥន្ធនៈលើដី (Fuel Filling Station)

☐ ស្ថានីយប្រេងឥន្ធនៈលើទឹក (Floating Fuel Filling Station)

☐ ស្ថានីយឧស្ម័នឥន្ធនៈ (Gas Filling Station)

☐ ស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ (Joint Fuel and Gas Filling Station)

**២.២- ព័ត៌មានអំពីការសាងសង់** (Information on Construction)

☐ មិនទាន់សាងសង់ (Not yet constructed) ☐ កំពុងសាងសង់ (Constructing) ☐ កំពុងដំណើរការ (Operating)

កាលបរិច្ឆេទចាប់ផ្តើមសាងសង់ (Construction Commencement Date): ______

កាលបរិច្ឆេទបញ្ចប់ការសាងសង់ (Construction Completion Date): ______

កាលបរិច្ឆេទដាក់ឱ្យដំណើរការ (Commissioning Date): ______

**២.៣- ព័ត៌មានអំពីទីតាំងស្ថានីយ** (Information on Filling Station Location)

ឈ្មោះ ឬ ស្លាកយីហោស្ថានីយ (Name of Filling Station): ______

អាសយដ្ឋានស្ថានីយ (Address of Filling Station): ______

______

ទំហំផ្ទៃដីសរុប - ម៉ែត្រក្រឡា (Land Area, $m^2$) ______ ប្រវែងក្បាលដី (Width) ______ ម៉ែត្រ(m) ប្រវែងជម្រៅដី (Length) ______ ម៉ែត្រ(m)

ក្រសួងរ៉ែ និងថាមពល

| សម្រាប់មន្ត្រីបំពេញ ( For Official ) | |
|---|---|
| មាន | គ្មាន |

**៣- ឯកសារភ្ជាប់មកជាមួយ** (Attached Documents):

| | | មាន | គ្មាន |
|---|---|---|---|
| ☐ រូបថតម្ចាស់ស្ថានីយ ៤x៦ (Photos of Filling Station Owner 4x6) | ចំនួន ៣ សន្លឹក (3 Photos) | ☐ | ☐ |
| ☐ ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (Copy of ID or Passport) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្នុងករណីជានីតិបុគ្គល) (Copy of Statute and Certificate of Business Registration, If Legal Entity) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ គំនូសប្លង់ទិដ្ឋភាពរួមជុំវិញស្ថានីយ (Diagram Showing the Facilities Surrounding the Filling Station) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ គំនូសប្លង់ទិដ្ឋភាពរួមក្នុងបរិវេណស្ថានីយ (Diagram Showing the Facilities Inside the Filling Station) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |

**ឯកសារបង់ប្រាក់**
**លេខ៖**..................
☐ ពេញលេញ
☐ មិនពេញលេញ

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។
I, hereby, declare that the information given in this application including all attached supporting documents are true and correct.

ថ្ងៃ...................... ខែ.................. ឆ្នាំ.............. ព.ស......................
ថ្ងៃទី(Day).............ខែ(Month)...................ឆ្នាំ(Year) ..................

ហត្ថលេខា និងឈ្មោះមន្ត្រីទទួលពាក្យ
(Signature and Name of Official)

ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ
(Signature and Name of Applicant)

ឈ្មោះ (Name):............................................
កាលបរិច្ឆេទ(Date):......................................

# ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ប្រព្រឹត្តកម្ម

APPLICATION FORM FOR SAFETY TECHNICAL CERTIFICATE FOR PROCESSING

**១- ព័ត៌មានអំពីអ្នកស្នើសុំ (Applicant's Information)**

☐ រូបវន្តបុគ្គល (Natural Person) ☐ នីតិបុគ្គល (Legal Entity)

ឈ្មោះអ្នកស្នើសុំ៖ ____________ សញ្ជាតិ៖ ____________ ភេទ៖ ☐ ប្រុស ☐ ស្រី

Applicant's Name: ____________ Nationality: ____________ Sex: ☐ Male ☐ Female

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number): ____________ ថ្ងៃខែឆ្នាំកំណើត (DoB): ____________

អាសយដ្ឋានអ្នកស្នើសុំ (Address of Applicant): ____________

____________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____________ អ៊ីម៉ែល (E-mail): ____________

| |
|---|
| បំពេញព័ត៌មានខាងក្រោម ប្រសិនបើម្ចាស់អាជីវកម្មជានីតិបុគ្គល (Complete the Following If the Applicant is a Legal Entity)៖ |
| តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន ៖ ☐ ប្រធានក្រុមហ៊ុន (Chairman/Managing Director) |
| Position of Applicant in Company/Firm : ☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (Duly Representative) |
| (សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង Please Attach Power of Attorney) |
| នាមករណ៍ក្រុមហ៊ុន ៖ ____________ លេខចុះបញ្ជីពាណិជ្ជកម្ម : ____________ |
| Firm/Company's Name : ____________ (Business Registration No) |
| អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ (Office's Address) : ____________ |
| លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____________ អ៊ីម៉ែល (E-mail) : ____________ |

**២- ព័ត៌មានអំពីគម្រោងរោងចក្រប្រព្រឹត្តិកម្ម (Information on Processing Plant Project)**

**២.១- ប្រភេទរោងចក្រប្រព្រឹត្តិកម្ម (Type of Processing Plant)**

☐ រោងចក្រចម្រាញ់ប្រេងកាត (Oil Refinery)

☐ រោងចក្រប្រព្រឹត្តិកម្មឧស្ម័ន (Gas Processing Plant)

☐ រោងចក្រប្រព្រឹត្តិកម្មគីមីប្រេងកាត (Petrochemical Processing Plant)

☐ ផ្សេងទៀត-សូមបញ្ជាក់ (Other-please specify)៖ ____________

**២.២- ព័ត៌មានអំពីទីតាំងរោងចក្រប្រព្រឹត្តិកម្ម (Information on Processing Plant Location)**

ឈ្មោះក្រុមហ៊ុន ឬទីតាំងប្រព្រឹត្តិកម្ម (Name of Processing Plant): ____________

អាសយដ្ឋានទីតាំងរោងចក្រប្រព្រឹត្តិកម្ម (Address of Processing Plant): ____________

____________

ព្រំដីទីតាំងរោងចក្រប្រព្រឹត្តិកម្មប៉ែកខាងជើង (The North Border of Processing Plant): ____________

ព្រំដីទីតាំងរោងចក្រប្រព្រឹត្តិកម្មប៉ែកខាងត្បូង (The South Border of Processing Plant): ____________

ព្រំដីទីតាំងរោងចក្រប្រព្រឹត្តិកម្មប៉ែកខាងកើត (The East Border of Processing Plant): ____________

ព្រំដីទីតាំងរោងចក្រប្រព្រឹត្តិកម្មប៉ែកខាងលិច (The West Border of Processing Plant): ____________

ទំហំផ្ទៃដីសរុប - ម៉ែត្រក្រឡា (Land Area, $m^2$) ____________ ប្រវែងក្បាលដី (Width) ____________ ប្រវែងជម្រៅដី (Length) ____________

**២.៣- ព័ត៌មានអំពីសមត្ថភាពរោងចក្រប្រព្រឹត្តិកម្ម (Information on the Capacity of Processing Plant)**

សមត្ថភាពផលិតក្នុង១ឆ្នាំ (Processing Capacity per Year): ____________ លីត្រ(Litter) ☐ ____________ តោន(Ton) ☐

**២.៤- ព័ត៌មានអំពីទុនវិនិយោគ (Information on Investment Capital)**

តម្លៃប៉ាន់ស្មានទុនវិនិយោគសរុប (Estimated Total Investment Capital): ____________________

**៣- ព័ត៌មានអំពីបរិក្ខារសំខាន់ៗ** (Information on the Important Facilities)

អ្នកស្នើសុំត្រូវបំពេញតារាងបញ្ជីបរិក្ខារសំខាន់ៗដូចខាងក្រោម (Please fill in the list of important facilities as below):

| ល.រ | បរិក្ខារបច្ចេកទេស (Technical Facilities) | ឯកតា (Unit) | បរិមាណ (Quantity) | ប្រភព(Source) | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក (Domestic) | នាំចូលពី(Import from) |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |

*សូមភ្ជាប់មកជាមួយនូវយថាប្រភេទនៃបរិក្ខារនីមួយៗ (Please attach the specifications of each facility)

**៤- ព័ត៌មានអំពីវត្ថុធាតុដើម** (Information on Raw Materials)

អ្នកស្នើសុំត្រូវបំពេញតារាងបញ្ជីវត្ថុធាតុដើមចាំបាច់សម្រាប់រោងចក្រប្រព្រឹត្តិកម្ម ដូចខាងក្រោម (Please fill in the list of the main raw materials for the processing plant as below):

| ល.រ | វត្ថុធាតុដើម (Raw Materials) | ឯកតា (Unit) | បរិមាណ (Quantity) | ប្រភព(Source) | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក (Domestic) | នាំចូលពី(Import from) |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |

*សូមភ្ជាប់មកជាមួយនូវយថាប្រភេទនៃវត្ថុធាតុដើមនីមួយៗប្រសិនបើមាន (Please attach the specifications of each raw material, if available)

**៥- ព័ត៌មានអំពីផលិតផល** (Information on Products)

អ្នកស្នើសុំត្រូវបំពេញបញ្ជីផលិតផលដែលគ្រោងផលិតក្នុងតារាងខាងក្រោម (Please fill in the list of products to be produced as below)៖

| ល.រ | ផលិតផល (Products) | ឯកតា (Unit) | បរិមាណ (Quantity) | ទីផ្សារ(Market) | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក (Domestic) | នាំចេញ(Export to) |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |

*សូមភ្ជាប់មកជាមួយនូវយថាប្រភេទនៃផលិតផលនីមួយៗ (Please attach the specification of each products)

**៦. ព័ត៌មានអំពីការសាងសង់** (Information on Construction)

កាលបរិច្ឆេទចាប់ផ្តើមសាងសង់ (Construction Commencement Date): ____________________

កាលបរិច្ឆេទបញ្ចប់ការសាងសង់ (Construction Completion Date): ____________________

កាលបរិច្ឆេទដាក់ឱ្យដំណើរការ (Commissioning Date): ____________________

**៧- ឯកសារដែលត្រូវភ្ជាប់មកជាមួយ** (Attached Documents):

| | | សម្រាប់មន្ត្រីបំពេញ (For Official) មាន | គ្មាន |
|---|---|---|---|
| ☐ សាវតាក្រុមហ៊ុនដែលស្នើសុំ(Company Profile) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (Copy of ID or Passport) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្នុងករណីជានីតិបុគ្គល) (Copy of Statute and Certificate of Business Registration, If Legal Entity) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ ផែនការអាជីវកម្ម ឬ របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព (Business Plan or Feasibility Study Report) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ គំនូសប្លង់បច្ចេកទេសរៀបចំរោងចក្រប្រព្រឹត្តិកម្ម (Technical Drawing of Processing Plant) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| | | ☐ ពេញលេញ | |
| | | ☐ មិនពេញលេញ | |

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។

I, hereby, declare that the information given in this application including all attached supporting documents are true and correct.

ថ្ងៃ.................... ខែ.................ឆ្នាំ............ ព.ស......................

ថ្ងៃទី(Day).............ខែ(Month)................ ឆ្នាំ(Year) ..............

ហត្ថលេខា និងឈ្មោះមន្ត្រីទទួលពាក្យ
(Signature and Name of Official)

ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ
(Signature and Name of Applicant)

ឈ្មោះ (Name):...........................................

កាលបរិច្ឆេទ(Date):.......................................

# ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សន្និធិ
APPLICATION FORM FOR SAFETY TECHNICAL CERTIFICATE FOR STORAGE

**១- ព័ត៌មានអំពីអ្នកស្នើសុំ (Applicant's Information)**

☐ រូបវន្តបុគ្គល (Natural Person) ☐នីតិបុគ្គល (Legal Entity)

ឈ្មោះអ្នកស្នើសុំ៖ ________ សញ្ជាតិ៖ ________ ភេទ៖ ☐ ប្រុស ☐ ស្រី

Applicant's Name: ________ Nationality: ________ Sex: ☐ Male ☐ Female

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number): ________ ថ្ងៃខែឆ្នាំកំណើត (DoB): ________

អាសយដ្ឋានអ្នកស្នើសុំ (Address of Applicant): ________

________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ________ អ៊ីម៉ែល (E-mail): ________

បំពេញព័ត៌មានខាងក្រោម ប្រសិនបើម្ចាស់អាជីវកម្មជានីតិបុគ្គល (Complete the Following If the Applicant is a Legal Entity)៖

តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន ៖ ☐ ប្រធានក្រុមហ៊ុន (Chairperson/Managing Director)

Position of Applicant in Company/Firm : ☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (Duly Representative)

(សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង Please Attach Power of Attorney)

នាមករណ៍ក្រុមហ៊ុន ៖ ________ លេខចុះបញ្ជីពាណិជ្ជកម្ម : ________

Firm/Company's Name : ________ (Business Registration No)

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ (Office's Address) : ________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ________ អ៊ីម៉ែល (E-mail) : ________

**២- ព័ត៌មានអំពីគម្រោងមណ្ឌលសន្និធិ (Information on Storage Terminal Project)**

**២.១- ប្រភេទមណ្ឌលសន្និធិ (Type of Storage Terminal)**

☐ មណ្ឌលសន្និធិប្រេងឥន្ធនៈ (Fuel Storage Terminal)

☐ មណ្ឌលសន្និធិឧស្ម័នឥន្ធនៈ (Gas Storage Terminal)

☐មណ្ឌលសន្និធិរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ (Joint Fuel and Gas Storage Terminal)

☐ ផ្សេងទៀត សូមបញ្ជាក់(Other-please specify): ________

**២.២- ព័ត៌មានអំពីទីតាំងមណ្ឌលសន្និធិ (Information on Storage Terminal Location)**

ឈ្មោះមណ្ឌលសន្និធិ ( Name of Storage Terminal): ________

អាសយដ្ឋានមណ្ឌលសន្និធិ (Address of Storage Terminal): ________

________

ទំហំផ្ទៃដីសរុប - ម៉ែត្រក្រឡា (Land Area, $m^2$ ) : ________ ប្រវែងក្បាលដី (Width) ________ ប្រវែងជម្រៅដី(Length) ________

ព្រំដីទីតាំងមណ្ឌលសន្និធិបែកខាងជើង (The North Border of Storage Terminal): ________

ព្រំដីទីតាំងមណ្ឌលសន្និធិបែកខាងត្បូង (The South Border of Storage Terminal): ________

ព្រំដីទីតាំងមណ្ឌលសន្និធិបែកខាងកើត (The East Border of Storage Terminal): ________

ព្រំដីទីតាំងមណ្ឌលសន្និធិបែកខាងលិច (The West Border of Storage Terminal): ________

**២.៣- ព័ត៌មានអំពីបរិមាណសន្និធិ (Information on Storage Capacity)**

☐ បរិមាណសន្និធិប្រេងឥន្ធនៈសរុប ( Total Capacity of Fuel Storage Terminal): ________

☐ បរិមាណសន្និធិឧស្ម័នឥន្ធនៈសរុប ( Total Capacity of Gas Storage Terminal): ________

**២.៤- ព័ត៌មានអំពីសម្ភារៈនិងឋបនភណ្ឌបច្ចេកទេស (Information on Technical Equipment and Facilities)**

**២.៤.១. ពាង** (Storage Tanks)

ចំនួនពាងសរុប (Number of Storage Tanks) ____

ពាងទី១ (1st Tank) ៖ ប្រភេទផលិតផល (Type of Product) ____ ចំណុះ (Volume) ____ ☐លីត្រ (Littre) ☐តោន (Ton)
☐កប់ដី(Underground) ☐ ក្នុងដី(Inner Ground) ☐ ដាក់លើដី(Above Ground)

ពាងទី២ (2nd Tank) ៖ ប្រភេទផលិតផល (Type of Product) ____ ចំណុះ (Volume) ____ ☐លីត្រ (Littre) ☐តោន (Ton)
☐កប់ដី(Underground) ☐ ក្នុងដី(Inner Ground) ☐ ដាក់លើដី(Above Ground)

ពាងទី៣ (3rd Tank) ៖ ប្រភេទផលិតផល (Type of Product) ____ ចំណុះ (Volume) ____ ☐លីត្រ (Littre) ☐តោន (Ton)
☐កប់ដី(Underground) ☐ ក្នុងដី(Inner Ground) ☐ ដាក់លើដី(Above Ground)

ពាងទី៤ (4th Tank) ៖ ប្រភេទផលិតផល (Type of Product) ____ ចំណុះ (Volume) ____ ☐លីត្រ (Littre) ☐តោន (Ton)
☐កប់ដី(Underground) ☐ ក្នុងដី(Inner Ground) ☐ ដាក់លើដី(Above Ground)

ពាងទី៥ (5th Tank) ៖ ប្រភេទផលិតផល (Type of Product) ____ ចំណុះ (Volume) ____ ☐លីត្រ (Littre) ☐តោន (Ton)
☐កប់ដី(Underground) ☐ ក្នុងដី(Inner Ground) ☐ ដាក់លើដី(Above Ground)

ពាងទី៦ (6th Tank) ៖ ប្រភេទផលិតផល (Type of Product) ____ ចំណុះ (Volume) ____ ☐លីត្រ (Littre) ☐តោន (Ton)
☐កប់ដី(Underground) ☐ ក្នុងដី(Inner Ground) ☐ ដាក់លើដី(Above Ground)

ពាងទី៧ (7th Tank) ៖ ប្រភេទផលិតផល (Type of Product) ____ ចំណុះ (Volume) ____ ☐លីត្រ (Littre) ☐តោន (Ton)
☐កប់ដី(Underground) ☐ ក្នុងដី(Inner Ground) ☐ ដាក់លើដី(Above Ground)

ពាងទី៨ (8th Tank) ៖ ប្រភេទផលិតផល (Type of Product) ____ ចំណុះ (Volume) ____ ☐លីត្រ (Littre) ☐តោន (Ton)
☐កប់ដី(Underground) ☐ ក្នុងដី(Inner Ground) ☐ ដាក់លើដី(Above Ground)

**២.៤.២. ប្រព័ន្ធផ្ទេរចេញ ចូល (Loading-unloading System)**

- ការផ្ទេរចូលពី៖ ☐ រថយន្តស៊ីទែន (Tank Truck) ☐ រថភ្លើង (Train) ☐ ផែផ្ទេរ (Jetty)
- ការផ្ទេរចេញពី៖ ☐ រថយន្តស៊ីទែន (Tank Truck) ☐ រថភ្លើង (Train) ☐ ផែផ្ទេរ (Jetty)

**២.៤.៣. ប្រព័ន្ធទំនប់ការពារការលេចធ្លាយ** (Leakage Protection Dam System)៖ ☐ មាន(Yes) ☐ គ្មាន (No)

**២.៤.៤ អំពីប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ** (Firefighting Protection System)៖ ☐ មាន(Yes) ☐ គ្មាន (No)

**២.៤.៥ អំពីប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក** (Oil-Water Separation System)៖ ☐ មាន(Yes) ☐ គ្មាន (No)

**២.៤.៦ ព័ត៌មានអំពីការសាងសង់**

កាលបរិច្ឆេទចាប់ផ្ដើមសាងសង់ (Construction Commencement Date): ____

កាលបរិច្ឆេទបញ្ចប់ការសាងសង់ (Construction Completion Date): ____

កាលបរិច្ឆេទដាក់ឱ្យដំណើរការ (Commissioning Date): ____

**៣- ឯកសារភ្ជាប់មកជាមួយ** (Attaching Documents) :

| | | សម្រាប់មន្ត្រីបំពេញ (For Official) មាន | គ្មាន |
|---|---|---|---|
| ☐ សាវតាក្រុមហ៊ុនដែលស្នើសុំ(Company Profile) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (Copy of ID or Passport) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្នុងករណីជានីតិបុគ្គល) (Copy of Statute and Certificate of Business Registration, If Legal Entity) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ ផែនការអាជីវកម្ម ឬ របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព (Business Plan or Feasibility Study Report) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ គំនូសប្លង់បច្ចេកទេសរៀបចំមណ្ឌលសន្និធិ (Technical Drawing of Storage Terminal) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |

☐ ពេញលេញ
☐ មិនពេញលេញ

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។
I, hereby, declare that the information given in this application including all attached supporting documents are true and correct.

ថ្ងៃ..................... ខែ.................ឆ្នាំ............ ព.ស.....................
ថ្ងៃទី(Day)...........ខែ(Month)...............ឆ្នាំ(Year) ...........
ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ
(Signature and Name of Applicant)

ហត្ថលេខា និងឈ្មោះមន្ត្រីទទួលពាក្យ
(Signature and Name of Official)

ឈ្មោះ (Name):............................................
កាលបរិច្ឆេទ(Date):......................................

ទម្រង់ ១.១.៤

# ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការដឹកជញ្ជូនតាមបំពង់បង្ហូរ

APPLICATION FORM FOR SAFETY TECHNICAL CERTIFICATE FOR PIPELINE TRANSPORTATION

**១- ព័ត៌មានអំពីអ្នកស្នើសុំ (Applicant's Information)**

☐នីតិបុគ្គល (Legal Entity)

ឈ្មោះអ្នកស្នើសុំ៖______ សញ្ញាតិ៖______ ភេទ៖ ☐ ប្រុស ☐ ស្រី

Applicant's Name:______ Nationality:______ Sex: ☐ Male ☐ Female

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number):______ ថ្ងៃខែឆ្នាំកំណើត (DoB):______

អាសយដ្ឋានអ្នកស្នើសុំ (Address of Applicant):______

______

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) :______ អ៊ីម៉ែល (E-mail):______

តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន ៖ ☐ ប្រធានក្រុមហ៊ុន (Chairperson/Managing Director)

Position of Applicant in Company/Firm : ☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (Duly Representative)

(សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង Please Attach Power of Attorney)

នាមករណ៍ក្រុមហ៊ុន ៖______ លេខចុះបញ្ជីពាណិជ្ជកម្ម :______

Firm/Company's Name :______ (Business Registration No)

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ (Office's Address) :______

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) :______ អ៊ីម៉ែល (E-mail) :______

**២- ព័ត៌មានអំពីគម្រោងបំពង់បង្ហូរ** (Information on Pipeline Project)

**២.១- ប្រភេទបំពង់បង្ហូរ** (Type of Pipeline)

☐ បំពង់បង្ហូរប្រេងឆៅ (Crude Oil Pipeline)

☐ បំពង់បង្ហូរផលិតផលប្រេងកាត (Petroleum Products Pipeline)

☐បំពង់បង្ហូរឧស្ម័នធម្មជាតិ (Natural Gas Pipeline)

**២.២- ព័ត៌មានអំពីបំពង់បង្ហូរ** (Information on the Pipeline)

ឈ្មោះគម្រោងបំពង់បង្ហូរ( Name of Pipeline Project):______

ប្រវែងបំពង់បង្ហូរសរុប (Total Length of Pipeline) :______ គីឡូម៉ែត្រ (km)

ចាប់ពី (From)______ ទៅដល់ (To)______

ចំនួនអនុស្ថានីយបញ្ជូន (Numbers of sub-stations for transferring)):______

ទំហំបំពង់បង្ហូរ (Pipeline Size) :______ មីលីម៉ែត្រ (mm)

សមត្ថភាពបញ្ជូនសរុបក្នុងមួយឆ្នាំ (Capacity of Transportation per year):______ លីត្រ (Litter)☐ /តោន (Ton)☐

**២.៣- ព័ត៌មានអំពីទុនវិនិយោគ** (Information on Investment Capital)

តម្លៃប៉ាន់ស្មានទុនវិនិយោគសរុប (Total Estimated Investment Capital):______

**៣. អំពីការសាងសង់**

កាលបរិច្ឆេទចាប់ផ្តើមសាងសង់ (Construction Commencement Date):______

កាលបរិច្ឆេទបញ្ចប់ការសាងសង់ (Construction Completion Date):______

កាលបរិច្ឆេទដាក់ឱ្យដំណើរការ (Commissioning Date):______

**៤- ឯកសារភ្ជាប់មកជាមួយ** (Attached Documents) :

| | | សម្រាប់មន្ត្រីបំពេញ (For Official) មាន | គ្មាន |
|---|---|---|---|
| ☐ សាវតាក្រុមហ៊ុនដែលស្នើសុំ(Company Profile) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (Copy of ID or Passport) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |

| | | |
|---|---|---|
| ☐ ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្នុងករណីជានីតិបុគ្គល) (Copy of Statute and Certificate of Business Registration, If Legal Entity) | ចំនួន ១ ច្បាប់ (1 copy) | ☐ ☐ |
| ☐ ផែនការអាជីវកម្ម ឬ របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព (Business Plan or Feasibility Study Report) | ចំនួន ១ ច្បាប់ (1 copy) | ☐ ☐ |
| ☐ គំនូសប្លង់បច្ចេកទេសរៀបចំប្រព័ន្ធបំពង់បង្ហូរ (Technical Drawing of Pipeline System) | ចំនួន ១ ច្បាប់ (1 copy) | ☐ ☐ |
| | | ☐ ពេញលេញ<br>☐ មិនពេញលេញ |

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។
I, hereby, declare that the information given in this application including all attached supporting documents are true and correct.

ថ្ងៃ...................... ខែ................. ឆ្នាំ............ ព.ស........................

ថ្ងៃទី(Day).............ខែ(Month)................ ឆ្នាំ(Year) ...............

ហត្ថលេខា និងឈ្មោះមន្ត្រីទទួលពាក្យ
(Signature and Name of Official)

ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ
(Signature and Name of Applicant)

ឈ្មោះ (Name):...........................................
កាលបរិច្ឆេទ(Date):........................................

# ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ

## APPLICATION FORM FOR SAFETY TECHNICAL CERTIFICATE FOR NON-PIPELINE TRANSPORTATION

**១- ព័ត៌មានអំពីអ្នកស្នើសុំ (Applicant's Information)**

☐ រូបវន្តបុគ្គល (Natural Person) ☐នីតិបុគ្គល (Legal Entity)

ឈ្មោះអ្នកស្នើសុំ៖ ____________ សញ្ជាតិ៖ ____________ ភេទ៖ ☐ ប្រុស ☐ ស្រី

Applicant's Name: ____________ Nationality: ____________ Sex: ☐ Male ☐ Female

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number): ____________ ថ្ងៃខែឆ្នាំកំណើត (DoB): ____________

អាសយដ្ឋានអ្នកស្នើសុំ (Address of Applicant): ____________

____________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____________ អ៊ីម៉ែល (E-mail): ____________

បំពេញព័ត៌មានខាងក្រោម ប្រសិនបើម្ចាស់អាជីវកម្មជានីតិបុគ្គល (Complete the Following If the Applicant is a Legal Entity)៖

តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន ៖ ☐ ប្រធានក្រុមហ៊ុន (Chairperson/Managing Director)

Position of Applicant in Company/Firm : ☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (Duly Representative)

(សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង Please Attach Power of Attorney)

នាមករណ៍ក្រុមហ៊ុន ៖ ____________ លេខចុះបញ្ជីពាណិជ្ជកម្ម :

Firm/Company's Name : ____________ (Business Registration No)

អាសយដ្ឋានស្នាក់ការអេចិន្ត្រៃយ៍ (Office's Address) : ____________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) : ____________ អ៊ីម៉ែល (E-mail) : ____________

**២- ព័ត៌មានអំពីគម្រោងដឹកជញ្ជូន (Information on Transportation Project)**

**២.១- ប្រភេទមធ្យោបាយដឹកជញ្ជូន (Type of Transportation Means)**

☐ រថយន្តស៊ីទែន (Tank Truck) ☐ រថភ្លើង (Train) ☐ កប៉ាល់/នាវា (Ship/Vessel)

**២.២- ព័ត៌មានអំពីការដឹកជញ្ជូន (Information on Transportation)**

ឈ្មោះ ឬយីហោអាជីវកម្ម( Name of Transportation Business): ____________

អាសយដ្ឋានទីតាំងអាជីវកម្មដឹកជញ្ជូន (Address of the Transportation Business location): ____________

____________

សមត្ថភាពដឹកបញ្ជូនសរុបក្នុងមួយឆ្នាំ (Capacity of Transportation per year): ____________ លីត្រ (Litter)☐ /តោន (Ton)☐

**២.៣- ព័ត៌មានអំពីទុនវិនិយោគ (Information of Investment Capital)**

តម្លៃប៉ាន់ស្មានទុនវិនិយោគសរុប (Estimated Total Investment Capital) ____________

**២.៤- ព័ត៌មានអំពីមធ្យោបាយដឹកជញ្ជូន (Information on Transportation Means)**

ចំនួនមធ្យោបាយដឹកជញ្ជូន(Total Number of Transportation Means): ____________

មធ្យោបាយទី១ (1st Mean) ៖ ប្រភេទ (Type): ____________ ចំណុះ (Volume ): ____________ លីត្រ (Littre)/គីឡូក្រាម(Kg)

មធ្យោបាយទី២ (2nd Mean)៖ប្រភេទ (Type): ____________ ចំណុះ (Volume ): ____________ លីត្រ (Littre)/គីឡូក្រាម(Kg)

មធ្យោបាយទី៣ (3rd Mean) ៖ ប្រភេទ (Type): ____________ ចំណុះ (Volume ): ____________ លីត្រ (Littre)/គីឡូក្រាម(Kg)

មធ្យោបាយទី៤ (4th Mean) ៖ ប្រភេទ (Type): ____________ ចំណុះ (Volume ): ____________ លីត្រ (Littre)/គីឡូក្រាម(Kg)

មធ្យោបាយទី៥ (5th Mean) ៖ ប្រភេទ (Type): ____________ ចំណុះ (Volume ): ____________ លីត្រ (Littre)/គីឡូក្រាម(Kg)

មធ្យោបាយទី៦ (6th Mean) ៖ ប្រភេទ (Type): ____________ ចំណុះ (Volume ): ____________ លីត្រ (Littre)/គីឡូក្រាម(Kg)

មធ្យោបាយទី៧ (7th Mean) ៖ ប្រភេទ (Type): ____________ ចំណុះ (Volume ): ____________ លីត្រ (Littre)/គីឡូក្រាម(Kg)

(សូមធ្វើបញ្ជីបន្ថែម ប្រសិនបើមានមធ្យោបាយច្រើន Please fill in additional list, if there are more means)

| | | សម្រាប់មន្ត្រីបំពេញ (For Official) មាន | គ្មាន |
|---|---|---|---|
| **៣- ឯកសារភ្ជាប់មកជាមួយ** (Attached Documents) : | | | |
| ☐ សាវតាក្រុមហ៊ុនដែលស្នើសុំ (Company Profile) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (Copy of ID or Passport) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (Copy of Statute and Certificate of Business Registration) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ ផែនការអាជីវកម្ម (Business Plan) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ យថាប្រភេទមធ្យោបាយដឹកជញ្ជូននីមួយៗ (Specification of Each Transportation means) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| ☐ ច្បាប់ចម្លងបណ្ណសម្គាល់មធ្យោបាយដឹកជញ្ជូននីមួយៗ (Copy of Identification card of each transportation means) | ចំនួន ១ ច្បាប់ (1 copy) | ☐ | ☐ |
| | | ☐ ពេញលេញ | |
| | | ☐ មិនពេញលេញ | |

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។

I, hereby, declare that the information given in this application including all attached supporting documents are true and correct.

ថ្ងៃ.................... ខែ................ឆ្នាំ............ ព.ស....................

ថ្ងៃទី(Day)............ខែ(Month)................ឆ្នាំ(Year)...............

ហត្ថលេខា និងឈ្មោះមន្ត្រីទទួលពាក្យ
(Signature and Name of Official)

ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ
(Signature and Name of Applicant)

ឈ្មោះ (Name):...........................................
កាលបរិច្ឆេទ(Date):.......................................

# ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការវេចខ្ចប់
APPLICATION FORM FOR SAFETY TECHNICAL CERTIFICATE FOR BOTTLING/PACKAGING

**១- ព័ត៌មានអំពីអ្នកស្នើសុំ (Applicant's Information)**

☐នីតិបុគ្គល (Legal Entity)

ឈ្មោះអ្នកស្នើសុំ៖________________ សញ្ជាតិ៖__________ ភេទ៖ ☐ប្រុស ☐ស្រី

Applicant's Name:________________ Nationality:__________ Sex: ☐Male ☐Female

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number):__________ ថ្ងៃខែឆ្នាំកំណើត (DoB):__________

អាសយដ្ឋានអ្នកស្នើសុំ (Address of Applicant):________________

________________

លេខទូរស័ព្ទទំនាក់ទំនង (Telephone Number) :__________ អ៊ីម៉ែល (E-mail):__________

តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន ៖ ☐ប្រធានក្រុមហ៊ុន (Chairperson/Managing Director)

Position of Applicant in Company/Firm : ☐តំណាងស្របច្បាប់របស់ក្រុមហ៊ុន (Duly Representative)

(សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង Please Attach Power of Attorney)

នាមករណ៍ក្រុមហ៊ុន ៖________________ លេខចុះបញ្ជីពាណិជ្ជកម្ម :__________

